ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សាររំលែកមរណទុក្ខ

គោរពជូន

**លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី ព្រមទាំងក្រុមគ្រួសារ**

**ចំពោះមរណភាពរបស់ ឯកឧត្តម អ៊ឹង គៀត**

**លោកជំទាវកិត្តិបណ្ឌិត ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អានដ៏ជ្រាលជ្រៅ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្ដីសោកស្ដាយជាពន់ពេក ដោយបានទទួលដំណឹងថា **ឯកឧត្តម អ៊ឹង គៀត** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ជាឪពុករបស់លោកជំទាវបានទទួលមរណភាព នៅថ្ងៃពុធ ១៥កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង១១:៥០នាទីព្រឹក ក្នុងជន្មាយុ៩៨ឆ្នាំ ដោយជរាពាធ។

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្ដែងនូវសេចក្ដីសោកស្ដាយ ស្រណោះ អាឡោះអាល័យបំផុតជាមួយ **លោកជំទាវកិត្តិបណ្ឌិត ព្រមទាំងក្រុមគ្រួសារ** ចំពោះការបាត់បង់ **ឯកឧត្តម អ៊ឹង គៀត** ដែលជាលោកឪពុកដ៏ឧត្តម ជាឪពុកក្មេក ជាជីតាប្រកបដោយសង្គហធម៌ដ៏ល្អប្រពៃ ព្រហ្មវិហារធម៌មិនចេះរីងស្ងួត និងជាឥស្សរជនជាន់ខ្ពស់ នៃប្រទេសជាតិ និងរាស្ត្រកម្ពុជាដ៏ស្មោះត្រង់ ដែលបានចូលរួមបម្រើជាតិជាច្រើនជំនាន់យ៉ាងសកម្មបំផុត ក្នុងបុព្វហេតុ ជាតិ សាសនា ព្រះមហាក្សត្រ ។

ខ្ញុំសូមសម្ដែងនូវការគោរពចំពោះដួងវិញ្ញាណក្ខន្ធ **ឯកឧត្តម អ៊ឹង គៀត** សូមវិញ្ញាណក្ខន្ធឯកឧត្តមបានទៅសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវកិត្តិបណ្ឌិត ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ ៕

ថ្ងៃព្រហស្បតិ៍ ១រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២

រដ្ឋមន្ត្រី

ព្រុំ សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

